**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ :..១៥៣៣ សនណ

រាជធានីភ្នំពេញ ថ្ងៃទី២៣ខែ វិ ឆ្នាំ២០១០

**ជម្រាបមក**

**លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

**កម្មវត្ថុ** : ស្តីពីសំណើសុំប្រើឈ្មោះ **វិទ្យាស្ថានស្លឹករិត** ដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ចាប់ពីឆ្នាំ២០១១ នេះតទៅ។

**យោង** : លិខិតចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់លោក **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមក លោកនាយកថា ក្រសួងមហាផ្ទៃ ឯកភាពជាគោលការណ៍ អនុញ្ញាតឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រើប្រាស់ឈ្មោះ **វិទ្យាស្ថានស្លឹករិត** ដែលមានទីតាំងក្នុងបរិវេណវិទ្យាល័យបឹងត្របែក សម្រាប់បន្តដំណើរការ "ស្រាវជ្រាវឯកសារនានា ដែលមានការពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងនៅក្នុងបណ្តាប្រទេសទាំងឡាយដែលពាក់ព័ន្ធដល់ឯកសាររបបប្រល័យពូជសាសន៍" ដើម្បីបម្រើដល់ការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា តាមសំណើ។ ទន្ទឹមនេះ ដើម្បីឱ្យការប្រើប្រាស់ឈ្មោះវិទ្យាស្ថាននេះអាចទទួលយកបានពីគ្រប់មជ្ឈដ្ឋាន ស្នើលោកនាយក ធ្វើការសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនៅពេលដំណើរការ អនុវត្តការងារជាក់ស្តែងនៃវិទ្យាស្ថាននេះ។

អាស្រ័យហេតុនេះ សូមលោកនាយកជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើ តាមការគួរ។

សូមលោក ទទួលនូវការរាប់អាន ពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងអប់រំ យុវជន និងកីឡា

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-ក្រសួងធម្មការ និងកិច្ចការសាសនា

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-សាលារាជធានីភ្នំពេញ

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

(ជ្រាបជាព័ត៌មាន)

-ឯកសារ កាលប្បវត្តិ

Eco_Nith Chhang yunk 25-11-10